ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ០៣៥ ប្រ.ក បស្ក

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ «អន្លង់ជ្រៃ» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតក្នុងភូមិអន្លង់ជ្រៃ ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

៣*៧

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម០១២/០៦១៨/ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៧៤អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ព្រៃឡង់»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.** ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ«**អន្លង់ជ្រៃ**» នៃដែនជម្រកសត្វព្រៃ«ព្រៃឡង់» ស្ថិតក្នុងភូមិអន្លង់ជ្រៃ ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

**ប្រការ២.** សហគមន៍តំបន់ការពារធម្មជាតិ «**អន្លង់ជ្រៃ**» នៃដែនជម្រកសត្វព្រៃ«ព្រៃឡង់»មានផ្ទៃដីទំហំ **១២៦៩ ហិកតា** ដូចមានផែនទីជាឧបសម្ព័ន្ធកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា ដូចក្នុងតារាងខាងក្រោម៖



អគារមរតកតេជោ ផ្ទះលេខ៥០៣ ផ្លូវកៅស៊ូមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 568048 | 1507311 | 12 | 563122 | 1510378 |
| 2 | 566577 | 1507491 | 13 | 563665 | 1511440 |
| 3 | 565568 | 1507265 | 14 | 564023 | 1511308 |
| 4 | 564604 | 1507050 | 15 | 564959 | 1510391 |
| 5 | 563752 | 1507584 | 16 | 565863 | 1510182 |
| 6 | 563794 | 1508018 | 17 | 567544 | 1509604 |
| 7 | 563249 | 1508133 | 18 | 567502 | 1509199 |
| 8 | 563163 | 1508259 | 19 | 567874 | 1508338 |
| 9 | 562730 | 1508468 | 20 | 568003 | 1507743 |
| 10 | 562707 | 1508974 | 21 | 568384 | 1507705 |
| 11 | 562596 | 1509348 | | | |

**ប្រការ៣.** ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«អន្លង់ជ្រៃ»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.** សហគមន៍តំបន់ការពារធម្មជាតិ **«អន្លង់ជ្រៃ»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ សហគមន៍តំបន់ការពារធម្មជាតិ **«អន្លង់ជ្រៃ»** ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន។

**ប្រការ៥.** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកគ្រប់អគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង នាយកតំបន់ដែនជម្រកសត្វព្រៃ«ព្រៃឡង់» និងសហគមន៍តំបន់ការពារធម្មជាតិ **«អន្លង់ជ្រៃ»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ៍ ៣កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តស្ទឹងត្រែង
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិអន្លង់ថ្ងៃ ក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់

ភូមិសាស្ត្រភូមិអន្លង់ថ្ងៃ ឃុំអន្លង់ថ្ងៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ផ្ទៃដី១២៦៤ហិកតា




| Id | Labal | Coor_X | Coor_Y |
| --- | --- | --- | --- |
| 1 | A | 568048 | 1507311 |
| 2 | B | 566577 | 1507491 |
| 3 | C | 565568 | 1507265 |
| 4 | D | 564604 | 1507050 |
| 5 | E | 563752 | 1507584 |
| 6 | F | 563794 | 1508018 |
| 7 | G | 563249 | 1508133 |
| 8 | H | 563163 | 1508259 |
| 9 | I | 562730 | 1508468 |
| 10 | J | 562707 | 1508974 |
| 11 | K | 562596 | 1509348 |
| 12 | L | 563122 | 1510378 |
| 13 | M | 563665 | 1511440 |
| 14 | N | 564023 | 1511308 |
| 15 | O | 564959 | 1510391 |
| 16 | P | 565863 | 1510182 |
| 17 | Q | 567544 | 1509604 |
| 18 | R | 567502 | 1509199 |
| 19 | S | 567874 | 1508338 |
| 20 | T | 568003 | 1507743 |
| 21 | U | 568384 | 1507705 |